

ផេក សីហា ជា អ្នកណា ?

បច្ចុប្បន្នកាល នៅ ស្រុកខ្មែរ មាន ជន ? ឬ ព្រលឹង ? ឬ វត្ត ? ឬ អសុរកាយ ? រាល់ សញ្ញាសំនួរ ព្រោះ ការ: នោះ ដែល គេ មិន ស្គាល់ វា កំពុង បំពានច្បាប់ធម្មនុញ្ញ ជាក់ស្តែង ដោយ ថត ស ម្លេង សន្ទនា ជា ឯកជន តាម ទូរស័ព្ទ នៃ ពលរដ្ឋខ្មែរ ជា ពិសេស អ្នកនយោបាយ យក មក ចាក់ផ្សាយ ជា សាធារណ: តាម ទំនើងចិត្ត តែ ក្នាន អាជ្ញាធរ ស្វែងរកចាប់ តាម ច្បាប់ ជា ធរមាន។ និទ្ទណ្ណភាព នេះ អាច អោយ គេ សន្ទត បាន ថា ការ: នោះ ឬក៏ ជា អ្នក មាន អំណាច ខ្លាំងក្លា រស់នៅ នៅ លើ ច្បាប់ជាតិ ឬក៏ ជា អសុរកាយ កំណាច នាំ អោយ អជ្ញាធរ សស្លោ មិនហ៊ាន ទៅរកចាប់ ឬក៏ ជា ស្វ័យគម (robot) ពិសេស ដែល មិនទាន់ មាន ច្បាប់ ណាមួយ សំរាប់ ចោទប្រកាន់។

តែ ទុរចារ[1] នៃ ការ: នោះ សព្វថ្ងៃ វា មាន ហាន: (niveau) ជា អំពើ ភេរវកម្ម ចំពោះ សេរីភាព ឯកជន នៃ ប្រជាពលរដ្ឋ ខ្មែរ ព្រោះ ពលរដ្ឋ ម្នាក់ៗ អាចនឹង ទុក ទុរចារ នោះ ជា រិច្ចេ ទកម្ម ដល់ ភាពស្ងាត់កំបាំង (intimité) ជា ដាច់ខាត នៃ ជីវិត រស់នៅ ជា ឯកជន របស់ខ្លួន។ ហើយ ជួនកាល ទុរចារ និទ្ទណ្ណ នោះ វា ក្លាយ ជា របរ របស់ មនុស្សទុច្ចរិត សំរាប់ ចំរិត តាម

[1] ទុរចារ; ដំណើរប្រព្រឹត្តអាក្រក់។

ផេក សីហា ជា អ្នកណា ?

សេរីស្វែងរកប្រយោជន៍ ពី ជន ស្លូតត្រង់។ ដូច្នេះ គេ អាច ចាត់ទុក សកម្មភាព របស់ ការ: ផេក សីហា ជា ទោស តាមផ្លូវ ច្បាប់, ជា អំពើ អប្រិយ តាមផ្លូវ សីលធម៌ និង ជា អំពើ ដែល ធ្វើ អ្នកដទៃ ដោយ មន្តអាគម។ វិនិការ[2] របស់ ផេក សីហា ជា សកម្មភាព ទុច្ចរិត ទោះបី ផេក សីហា មាន ធម្មជាតិ ជា អ្វី ក៏ ដោយ ព្រោះ ជា សកម្មភាព ទុច្ចន្ទ: ដល់ បុគ្គលឯកជន ដែល ជា ភោគី (possesseur) នៃ សេរីភាព ជា ទ្រព្យសម្បត្តិឯកជន (domaine privé) ការពារ ដោយ ច្បាប់ សំរាប់ ការរស់នៅ ជា ធម្មតា ក្នុង ឋាន: ជា ពលរដ្ឋ។

ប៉ុន្តែ នៅ ស្រុកខ្មែរ មាន ច្បាប់រដ្ឋ តែ អ្នកអនុវត្ត វិនិច្ឆ័យ សេចក្តី ដោយ ឆន្ទាគតិ (លំអៀង) នាំ អោយ ផេក សីហា ក្លាយ ជា មនុស្សខ្លាំង អ្ករបី បំពាន សិទ្ធិ សេរីភាព អ្នកផង តាម សេរីថែម ទាំង មាន ក្រុម និស្សិត និង សាស្ត្រាចារ្យ ពួកែ ខាង ការ ចាក់ សំរាប់ ប្រតិបត្តិ សកម្មភាព ទុច្ចរិត របស់ខ្លួន។ ផេក សីហា ជា អ្នកណា ? បើទុក ជា មនុស្ស ឬ ព្រលឹង ឬ វត្ថុ ឬ អសុរ កាយ រ៉ាពិត ជា អ្ករ តា នៃ ទុល្លភអាសុចភាព[3] មាន នៅ ស្រុកខ្មែរ សព្វថ្ងៃ។

លោកឥតខ្ចាស វិនាសច្បាប់

---

[2] វិនិការ; ការធ្វើទុក្ខបុកម្នេញគេ។

[3] ទុល្លភអាសុចភាព; សេចក្តីស្អេកគ្រោក ក្ប្រមាន។